# ប្រព័ន្ធពលករជំនាញក្នុងវិស័យសម្អាតអគារ

## ～សម្រាប់ពលករជំនាញ ជាជនបរទេស～



អាត់តុហ្គីរ៉ូបារី អិលធីឌី

(គម្រោងឧបត្ថម្ភដោយក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព)

# សេចក្ដីផ្ដើម

ការប្រើប្រាស់សិទ្ធិស្នាក់នៅក្នុងនាមជា “ពលករជំនាញ” ត្រូវបានចាប់ផ្ដើមតាំងពីខែមេសា ឆ្នាំ2019។ វិស័យដែលអាចធ្វើការងារបានជា "ពលករជំនាញ"គឺបច្ចុប្បន្នមាន16ប្រភេទ វិស័យសម្អាតអគារចាប់ពីឆ្នាំ 2024 រយៈពេល5ឆ្នាំចំនួនអតិប្បរិមា37,000នាក់ ដែលរំពឹងថានឹងទទួលយក

សៀវភៅណែនាំនេះ រួមបញ្ចូលនូវចំណុចដូចខាងក្រោម៖

1. លក្ខណៈពិសេសនៃ "ពលករជំនាញ"
2. ដើម្បីធ្វើការក្នុងនាមជា “ពលករជំនាញលេខ1”
3. “ពលករជំនាញលេខ 1” ក្នុងវិស័យការងារសម្អាតអគារ
4. ការណែនាំអំពីផ្ដល់ជំនួយក្នុងការចូលមកកាន់ប្រទេសជប៉ុន និង ការផ្ដល់ជំនួយផ្នែករស់នៅ

ត្រូវបានធ្វើឡើង

ដើម្បី យល់អោយស៊ីជម្រៅស្ដីអំពីប្រព័ន្ធពលករជំនាញនិងការងារក្នុងវិស័យសម្អាតអគារ យើងសង្ឃឹមថាអ្នកនឹងប្រើប្រាស់សៀវភៅណែនាំនេះ

គម្រោងឧបត្ថម្ភដោយក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព
“ទម្រង់អង្កេតដើម្បីឱ្យមានភាពត្រឹមត្រូវចំពោះប្រព័ន្ធទទួលជនបរទេសក្នុងវិស័យសម្អាតអាគារ”
អ្នកទទួលបន្ទុកសម្រាប់ឆ្នាំ2024 ក្រុមហ៊ុន អាត់តុហ្គីរ៉ូបារី

# មាតិកា


**1សិទ្ធិស្នាក់នៅជា "ពលករជំនាញ " ..... 4**

1.1 លក្ខណៈពិសេសរបស់ "ពលករជំនាញលេខ1" ..... 4

1.2 លក្ខណៈពិសេសរបស់"ពលករជំនាញលេខ2" ..... 4

**2ដើម្បីធ្វើការដោយប្រើសិទ្ធិស្នាក់នៅជា "ពលករជំនាញលេខ1" ..... 5**

2.1 លក្ខខណ្ឌដើម្បីធ្វើការក្នុងនាមជា "ពលករជំនាញលេខ1" ..... 5

2.2លំដាប់លំដោយរហូតដល់ចូលធ្វើការ ..... 6

**3 "ពលករជំនាញ" ក្នុងវិស័យ សម្អាតអគារ ..... 10**

(1) ទីតាំងសម្អាត ..... 10

(2) របៀបសម្អាត ..... 11

(3) ការរីកចម្រើននៃការងារ ..... 12

(4) មតិរបស់សិស្សច្បងដែលធ្វើការនៅវិស័យ សម្អាតអគារ ..... 13

(5) វិធីស្វែងរកការងារ ..... 13

(6) ព័តមានការប្រលងភាសាជប៉ុន ប្រលងវាយតម្លៃពលករជំនាញលេខ1 ក្នុងវិស័យសម្អាតអគារ ..... 14

(7) របៀបរៀនសម្រាប់ការប្រលងវាយតម្លៃពលករជំនាញលេខ1ក្នុងវិស័យសម្អាតអគារ ..... 15

(8) ខ្លឹមសារនៃការប្រលងវាយតម្លៃពលករជំនាញលេខ1 ក្នុងវិស័យសម្អាតអគារ ..... 16

**4ការណែនាំអំពីផ្តល់ជំនួយក្នុងការចូល ប្រទេសជប៉ុន និង ការផ្តល់ជំនួយផ្នែករស់នៅ ..... 19**

**5សេចក្តីបញ្ចប់ ..... 20**

# 1សិទ្ធិស្នាក់នៅជា "ពលករជំនាញ "

## 1.1 លក្ខណៈពិសេសរបស់ “ពលករជំនាញលេខ1”

1. ពលករជំនាញ
   គឺជាប្រភេទសិទ្ធិស្នាក់នៅម្យ៉ាងរបស់ជនបរទេសដែលមានជំនាញក្នុងកម្រិតណាមួយក្នុងការបំពេញការងារ
   ដើម្បីដោះស្រាយបញ្ហានូវកង្វះមនុស្សដ៏ធ្ងន់ធ្ងរនៅប្រទេសជប៉ុន។
   ពលករជំនាញមាន ពលករជំនាញ លេខ1 និង លេខ2។
2. ករណីលោកអ្នកបានបញ្ចប់ហ្វឹកហ្វឺនជំនាញលេខ2 ក្នុងវិស័យសម្អាតអគារ នោះមានន័យថា លោកអ្នកបានបំពេញលក្ខខណ្ឌជាពលករជំនាញលេខ1។
3. ករណីអ្នកមិនបានបញ្ចប់ហ្វឹកហ្វឺនជំនាញលេខ2ក្នុងវិស័យសម្អាតអគារ ប៉ុន្តែបានប្រលងជាប់ (ការប្រលងជំនាញ/ការប្រលងភាសាជប៉ុន) នោះមានន័យថាអ្នកអាចបំពេញលក្ខខណ្ឌជា ពលករជំនាញលេខ1 បាន។[1]
4. ពលករជំនាញលេខ1 អាចធ្វើការរយៈពេលយូរបំផុត5ឆ្នាំ និង អាចផ្លាស់ប្តូរកន្លែងការងារបាន។

## 1.2 លក្ខណៈពិសេសរបស់“ពលករជំនាញលេខ2”

1. ប្រសិនបើបំពេញលក្ខខណ្ឌចាំបាច់ខាងក្រោម អាចផ្លាស់ពីពលករជំនាញលេខ1ទៅពលករជំនាញលេខ2បាន
   a. មានបទពិសោធន៍ការងារអនុវត្តខាងបង្ហាត់បង្ហាញបុគ្គលិក និងគ្រប់គ្រងការដ្ឋានលើសពី2ឆ្នាំ
   b. ប្រលងជាប់
      ការប្រលងវាយតម្លៃពលករជំនាញលេខ2ខាងវិស័យសម្អាតអគារ ឬ ការប្រលងជំនាញសម្អាតអគារកម្រិត1
2. ពលករជំនាញលេខ2 អាចធ្វើការបានដោយគ្មានរយៈពេលកំណត់ ក៏អាចនាំគ្រួសារមកជប៉ុនបានដែរ

[1] ករណីសិក្ខាកាម ផ្លាស់ប្តូរទៅជាពលករជំនាញលេខ1 ដែលស្ថិតនៅក្នុងវិស័យឧស្សាហកម្មប្រភេទដូចគ្នា នោះពុំចាំបាច់ប្រលងជាប់ (ការប្រលងជំនាញ/ការប្រលងភាសាជប៉ុន) ឡើយ។ ប៉ុន្តែ ប្រសិនបើក្រោយពីបញ្ចប់ហ្វឹកហ្វឺនជំនាញហើយចូលធ្វើការក្នុងនាមជាពលករជំនាញលេខ1 នៅក្នុងវិស័យឧស្សាហកម្មប្រភេទខុសគ្នា នោះចាំបាច់ត្រូវប្រលងជំនាញឱ្យជាប់។

# 2ដើម្បីធ្វើការដោយប្រើសិទ្ធិស្នាក់នៅជា "ពលករជំនាញលេខ1"

## 2.1 លក្ខខណ្ឌដើម្បីធ្វើការក្នុងនាមជា "ពលករជំនាញលេខ1"

ដើម្បីធ្វើការក្នុងនាមជាពលករជំនាញលេខ1ចាំបាច់ត្រូវបំពេញស្តង់ដាខាងក្រោម។

1. មានអាយុលើសពី18ឆ្នាំ
2. មានស្ថានភាពសុខភាពល្អ
3. មានលិខិតឆ្លងដែនដែលចេញដោយរដ្ឋាភិបាលបរទេសដែលនឹងសហការក្នុងការអនុវត្តការនិរទេសដោយរលូន។
4. គ្មានប្រាក់ធានា។ល។ត្រូវបានប្រមូលទេ
5. ប្រសិនបើអ្នកកំពុងបង់ថ្លៃសេវាទៅស្ថាប័នបរទេស អ្នកត្រូវតែយល់ និងយល់ព្រមទាំងស្រុងលើចំនួនទឹកប្រាក់ និងការវិភាគនៃការទូទាត់ជាមួយស្ថាប័ន
6. ប្រសិនបើប្រទេសបញ្ជូនបានបង្កើតនីតិវិធីដែលត្រូវអនុវត្តនោះនីតិវិធីទាំងនោះត្រូវតែធ្វើតាម
7. ស្តីអំពីអាហារ ការស្នាក់នៅ និងការចំណាយជាប្រចាំផ្សេងទៀតដែលជនបរទេសត្រូវបង់ យល់ព្រមដោយបានយល់យ៉ាងច្បាស់ចំពោះខ្លឹមសារនៃអត្ថប្រយោជន៍ដែលត្រូវបានផ្តល់ជូនជាតម្លៃនោះលើសពីនេះ ចំនួនទឹកប្រាក់នៃការចំណាយត្រូវតែស្មើនឹងការចំណាយជាក់ស្តែង ឬចំនួនសមស្របផ្សេងទៀត ហើយរបាយការណ៍លម្អិត ឬឯកសារផ្សេងទៀតត្រូវបានបង្ហាញ
8. អនុលោមតាមស្តង់ដារជាក់លាក់នៃវិស័យ (* បញ្ជាក់នៅក្នុងសេចក្តីជូនដំណឹងដែលចេញដោយក្រសួង និងស្ថាប័នរដ្ឋាភិបាលដែលទទួលខុសត្រូវលើវិស័យនេះ)

## 2.2លំដាប់លំដោយរហូតដល់ចូលធ្វើការ

### (1) ប្រសិនបើបច្ចុប្បន្ន កំពុងធ្វើការក្នុងនាមជាសិក្ខាកាមនៅប្រទេសជប៉ុន

ប្រលង → កិច្ចសម្ភាសន៍ជ្រើសរើស → នីតិវិធីសម្រាប់ការផ្លាស់ប្តូរសិទ្ធិនៃការស្នាក់នៅក្នុងប្រទេសជប៉ុន → ចូលធ្វើការ (ពលករជំនាញលេខ1)



- ប្រសិនបើសិក្ខាកាមក្នុងវិស័យសម្អាតអគារ បានបញ្ចប់ហ្វឹកហ្វឺនជំនាញលេខ 2 ដោយលទ្ធផលល្អ នោះពុំចាំបាច់ប្រលងតេស្តភាសាជប៉ុន ឬ ប្រលងវាយតម្លៃពលករជំនាញលេខ1 នៃវិស័យសម្អាតអគារឡើយ។
- ប្រសិនបើសិក្ខាកាមក្នុងវិស័យសម្អាតអគារ បានបញ្ចប់ហ្វឹកហ្វឺនជំនាញលេខ 2 ដោយលទ្ធផលល្អ នោះពុំចាំបាច់ប្រលងឱ្យជាប់តេស្តភាសាជប៉ុនទេ ប៉ុន្តែចាំបាច់ត្រូវប្រលងវាយតម្លៃពលករជំនាញលេខ1 នៃវិស័យសម្អាតអគារឱ្យជាប់ និង ត្រូវបានក្រុមហ៊ុនផ្នែកសម្អាតអគារទទួលឱ្យចូលធ្វើការ។
  សូមពិគ្រោះយោបល់ឱ្យច្បាស់ជាមួយនឹងក្រុមហ៊ុនដែលអ្នកកំពុងធ្វើការ ហើយចាប់ផ្តើមរៀនដើម្បីត្រៀមប្រលង និង ធ្វើសកម្មភាពផ្លាស់ប្តូរការងារ។

## (2) ប្រសិនបើបច្ចុប្បន្ន គឺជាសិស្សបរទេសដែលកំពុងស្នាក់នៅប្រទេសជប៉ុន




- បន្ទាប់ពីបញ្ចប់ការសិក្សាប្រសិនបើចង់ធ្វើការនៅប្រទេសជប៉ុនក្នុងនាមជាពលករជំនាញជនបរទេស ចាំបាច់ត្រូវប្រលងជាប់ភាសាជប៉ុន និង ការប្រលងវាយតម្លៃពលករជំនាញលេខ1វិស័យសម្អាតអគារ នឹង ទទួលបានការផ្តល់ជូនការងារពីក្រុមហ៊ុនសម្អាតអគារ។
- សម្រាប់ការងារក្រៅម៉ោងពេលកំពុងសិក្សាកំណត់ត្រឹម 28 ម៉ោងក្នុងមួយសប្តាហ៍គឺជាច្បាប់។ គោរពតាមច្បាប់ដើម្បីជៀសវាងបញ្ហានៅពេលផ្លាស់ប្តូរសិទ្ធិស្នាក់នៅរបស់អ្នកនាពេលអនាគត!

## (3) ប្រសិនបើបច្ចុប្បន្ន គឺជាអ្នកមានបទពិសោធន៍ការហ្វឹកហ្វឺនជំនាញកំពុងស្នាក់នៅបរទេស

### ប្រសិនបើលោកអ្នកបានបញ្ចប់ការហ្វឹកហ្វឺនជំនាញលេខ2 ក្នុងវិស័យសម្អាតអគារ

ពុំចាំបាច់ប្រលង → កិច្ចសម្ភាសន៍ជ្រើសរើស → និតិវិធីចូលប្រទេសជប៉ុន → ការចូលប្រទេសជប៉ុន → ចូលធ្វើការ (ពលករជំនាញលេខ1)



- ប្រសិនបើអ្នកបញ្ចប់សិក្ខាកាមលេខ 2 នៅក្នុងវិស័យសម្អាតអគារ ហើយត្រឡប់ទៅប្រទេសកំណើតរបស់អ្នកវិញ ក្នុងករណីអ្នកចង់ធ្វើការក្នុងវិស័យសម្អាតអគារនៅប្រទេសជប៉ុនទៀត អ្នកអាចធ្វើការម្តងទៀតក្រោមទិដ្ឋាការ "ពលករជំនាញលេខ 1" ។ ក្នុងករណីនេះ អ្នកនឹងមិនត្រូវបានតម្រូវឱ្យប្រឡងទេ ប៉ុន្តែអ្នកនឹងត្រូវឆ្លងកាត់នីតិវិធីចូលប្រទេសជប៉ុនម្តងទៀត។

## ប្រសិនបើលោកអ្នកបានបញ្ចប់ការហ្វឹកហ្វឺនជំនាញក្រៅពីវិស័យសម្អាតអគារ




- ប្រសិនបើលោកអ្នកបានបញ្ចប់ការហ្វឹកហ្វឺនជំនាញលេខ2 ក្រៅពីវិស័យសម្អាតអគារ នោះពុំចាំបាច់ប្រលងភាសាជប៉ុនទេ។
  ប៉ុន្តែលោកអ្នកចាំបាច់ត្រូវប្រលងវាយតម្លៃពលករជំនាញលេខ1 ក្នុងវិស័យសម្អាតអគារ ឱ្យជាប់។

## (4) ប្រសិនបើបច្ចុប្បន្ន កំពុងស្នាក់នៅបរទេស ហើយមិនមានបទពិសោធន៍ធ្វើ ការនៅប្រទេសជប៉ុន




- ប្រលងជាប់ភាសាជប៉ុន និង ការប្រលងវាយតម្លៃពលករជំនាញលេខ1នៃវិស័យសម្អាតអគារ[2]

---

[2]ប្រសិនបើការប្រលងវាយតម្លៃពលករជំនាញលេខ 1 វិស័យសម្អាតអគារមិនត្រូវបានធ្វើឡើងនៅក្នុងប្រទេសរបស់អ្នកទេក៏អាចមកប្រទេសជប៉ុនជាមួយនឹងស្ថានភាពស្នាក់នៅ "ការស្នាក់នៅរយៈពេលខ្លី" និងទៅប្រឡងនៅប្រទេសជប៉ុន។

# 3 “ពលករជំនាញ” ក្នុងវិស័យ សម្អាតអគារ

## (1) ទីតាំងសម្អាត

ធ្វើការសម្អាតនៅកន្លែងផ្សេងៗ ដូចជា ផ្សារទំនើប មន្ទីរពេទ្យ សណ្ឋាគារ ។ល។

សណ្ឋាគារ



ការិយាល័យធ្វើការ



ផ្សារទំនើប



មន្ទីរពេទ្យ



## (2)របៀបសម្អាត

ជាឧទាហរណ៍ មានដូចជា ការជូតសម្អាតកម្រាលឥដ្ឋនិងការបោសកម្រាលឥដ្ឋ ការលាងសម្អាតកន្លែងលាងមុខ បង្គន់







## (3) ការរីកចម្រើននៃការងារ

មានវិធីជាច្រើនសម្រាប់ការរីកចម្រើនការងារអាស្រ័យលើក្រុមហ៊ុន ប៉ុន្តែឧទាហរណ៍ជំហានដែលបង្ហាញក្នុងដ្យាក្រាមខាងក្រោមអាចត្រូវបានពិចារណា។




| កម្មករ | អ្នកបង្វឹក មេក្រុម | អ្នកទទួលបន្ទុកកន្លែងការងារ អ្នកគ្រប់គ្រងការងារ |
|---|---|---|
| គោលដៅគឺការចងចាំការងារនិងអាចអនុវត្តការងារបានជាប់លាប់តាមការណែនាំ | ធ្វើឱ្យការយល់ដឹងរបស់អ្នកកាន់តែស៊ីជម្រៅអំពីចំណុចការងារនៅនឹងកន្លែង និងរូបភាពរួម ហើយមានគោលបំណងចង់ក្លាយជាអ្នកបង្វឹក ឬមេក្រុម | មានគោលបំណងគ្រប់គ្រងការដ្ឋានទាំងមូល ផ្តល់ការណែនាំដល់សិស្សប្អូនបរទេស បង្កើតកម្មវិធីសិក្សាអប់រំ និងធ្វើការបណ្តុះបណ្តាល។ |

## (4)មតិរបស់សិស្សច្បុងដែលធ្វើការនៅវិស័យ សម្អាតអគារ

### សញ្ជាតិ : ថៃ (ភេទប្រុស)



- ខ្ញុំទៅកន្លែងសម្អាត(អគារការិយាល័យ) ជាមួយគ្នា 2～3នាក់
- ការធ្វើដំណើរទៅកាន់ទីតាំងមានឡានជូន ពុំមានអ្វីលំបាកទេ
- ខ្ញុំពេញចិត្តនឹងប្រាក់បៀវត្សបច្ចុប្បន្ន
- ខ្ញុំមិនគិតចង់ផ្លាស់ប្តូរការងារផ្នែកសម្អាតអគារនេះទេ

### សញ្ជាតិ : វៀតណាម (ភេទប្រុស)



- បុគ្គលិកនៅក្នុងក្រុមហ៊ុនបានបង្រៀនខ្ញុំពីការប្រលងវាយតម្លៃពលករជំនាញលេខ1 នៃ វិស័យសម្អាតអគារ ហើយខ្ញុំរៀនបានប្រហែល2សប្តាហ៍ ក៏អាចប្រលងជាប់
- សិស្សច្បុងនៅក្នុងក្រុមហ៊ុនភាគច្រើនជាមនុស្សរួសរាយ ហើយការងារក៏មានភាពសប្បាយ
- ខ្ញុំចង់ឆាប់ចេះបង្រៀនការងារទៅកាន់សិស្សប្អូនវិញ

### សញ្ជាតិ : មីយ៉ាន់ម៉ា (ភេទស្រី)



- ខ្ញុំធ្វើការសម្អាតនៅក្នុងសណ្ឋាគារ
- ខ្ញុំទទួលបន្ទុកការងារត្រួតពិនិត្យ ក្រោយពីបុគ្គលិកក្រៅម៉ោងបានសម្អាតរួច
- ជាចុងបញ្ចប់ ខ្ញុំចង់ធ្វើការងារផ្នែកត្រួតពិនិត្យ
- អ្នកគ្រប់គ្រងនៅកន្លែងការងារជាមនុស្សល្អណាស់ ហើយការងារមានភាពសប្បាយ

## (5)វិធីស្វែងរកការងារ

ក្រុមហ៊ុនសម្អាតអគារនៅប្រទេសជប៉ុន ប្រកាសស្វែងរកបុគ្គលិកតាមរយៈគេហទំព័រ ជាដើម ដូច្នេះ សូមលោកអ្នកសាកល្បងដាក់ពាក្យទៅកាន់ក្រុមហ៊ុនដែលខ្លួនចាប់អារម្មណ៍។ ឧទាហរណ៍ ASCF ក៏ផ្តល់ការគាំទ្រក្នុងការផ្គូផ្គងជាមួយក្រុមហ៊ុនផងដែរ។(សូមមើលទំព័រទី 15) មានគេហទំព័រព័ត៌មានការងារនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម។ល។សូមប្រយ័ត្ន ព្រោះមានករណីមិនល្អជាច្រើន"ត្រូវបានគេណែនាំ ការងារដែលមានលក្ខខណ្ឌល្អនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម ប៉ុន្តែនៅពេលទៅសាកល្បងគឺជាការងារខុសគ្នាទាំងស្រុង""វាមិនដូចអ្វីដែលខ្ញុំត្រូវបានលឺ" ឬ "ខ្ញុំបានផ្លាស់ប្តូរការងារ ប៉ុន្តែនៅទីបញ្ចប់វាមិនមានការងារធ្វើទេ"។

ទោះបីជាបានត្រឡប់ទៅប្រទេសកំណើតម្តងរួចហើយក៏ដោយ ក៏មានអ្នកខ្លះបានស្វែងរកការងារ ដោយ ទាក់ទងទៅស្ថាប័នបញ្ជូនពលករ និង ក្រុមហ៊ុនណែនាំធនធានមនុស្ស ជាដើម ហើយស្ថាប័ន ឬ ក្រុមហ៊ុននោះ បានណែនាំអំពីក្រុមហ៊ុនទៅអ្នកទាំងនោះ។

## (6)ព័តមានការប្រលងភាសាជប៉ុន ប្រលងវាយតម្លៃពលករជំនាញលេខ1 ក្នុងវិស័យសម្អាតអគារ

| | ការប្រលងសមត្ថភាពភាសាជប៉ុន | | តេស្តវាយតម្លៃពលករជំនាញលេខ1 |
|---|---|---|---|
| **ប្រភេទ** | តេស្តសមត្ថភាពភាសាជប៉ុន (JLPT)<br><br>https://www.jlpt.jp/ | ការធ្វើតេស្តភាសាជប៉ុនរបស់មូលនិធិជប៉ុន<br>(JFT-Basic)<br>https://www.jpf.go.jp/jft-basic/ | ការប្រលងវាយតម្លៃពលករជំនាញលេខ1ក្នុងវិស័យសម្អាតអគារ<br><br>https://www.j-bma.or.jp/qualification-training/zairyu |
| **ទីតាំងប្រលង** | ជប៉ុន<br>រួមទាំង90ជាងប្រទេស<br>និងតំបន់ផ្សេងទៀត | ជប៉ុន<br>រួមទាំង12ប្រទេស | ជប៉ុន ឥណ្ឌូណេស៊ី ហ្វីលីពីន ថៃ ស្រីលង្កាជាដើម |
| **ពេលប្រលង** | ខែកក្កដា ខែធ្នូ<br>(ទោះជាយ៉ាងនេះក្ដី ការប្រឡងនៅក្រៅប្រទេសអាចធ្វើឡើងក្នុងខែកក្កដា ឬខែធ្នូតែ1ដង។) | ស្ទើរតែរាល់ខែ | កាលវិភាគប្រលងនៅពេលបន្ទាប់<br>https://www.j-bma.or.jp/qualification-training/zairyu |
| **រយៈពេលប្រកាសលទ្ធផល** | ប្រហែល2ខែ | ថ្ងៃប្រលង | ថ្ងៃប្រលង |
| **ផ្សេងៗ** | សូមពិនិត្យមើលខាងក្រោម<br>ករណីតម្រូវឱ្យចេញលិខិតបញ្ជាក់ពិន្ទុតេស្តសមត្ថភាពភាសាជប៉ុន<br><br>https://www.jlpt.jp/certificate/index.html | លិខិតជូនដំណឹងលទ្ធផលប្រលង<br>គឺអាចមើលឃើញនៅលើវេបសាយក្នុងរយៈពេល៥ថ្ងៃនៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃប្រលង<br>http://ac.prometric-jp.com/testlist/jfe/index.html | ទម្រង់CBT (ការធ្វើតេស្ត・ផ្អែកលើ・កុំព្យូទ័រ)<br>លិខិតបញ្ជាក់ការប្រលងជាប់គឺត្រូវបានទាមទារសម្រាប់នីតិវិធីចូលប្រទេស<br><br>ការស្នើរសុំចេញលិខិតបញ្ជាក់ការប្រលងជាប់អាចធ្វើឡើងដោយស្ថាប័នម្ចាស់ផ្ទះ ឬបេក្ខជនដែលប្រលងជាប់ ខ្លួនឯង។ |

## (7) របៀបរៀនសម្រាប់ការប្រលងវាយតម្លៃពលករជំនាញលេខ1ក្នុងវិស័យសម្អាតអគារ

មានសៀវភៅជំនាញសម្រាប់ត្រៀមប្រលង និង វីដេអូណែនាំពីការងារសម្អាតអគារជាដើម។ សូមយកមកធ្វើជាឯកសារយោង!

**សៀវភៅសិក្សាត្រៀមប្រឡងពីសមាគមថែទាំអគារទូទាំងជប៉ុន** (ភាសាជប៉ុន និង ៨ ភាសាផ្សេងទៀត)
(លោកអ្នកអាចចូលមើលក្នុងគេហទំព័រ ឬ QRកូដ ដូចខាងក្រោម)
https://www.j-bma.or.jp/qualification-training/zairyu

**វីដេអូពន្យល់ដោយសង្ខេបអំពី ការប្រលងវាយតម្លៃពលករជំនាញលេខ1 ក្នុងវិស័យសម្អាតអគារ**
(លោកអ្នកអាចចូលមើលក្នុងគេហទំព័រ ឬ QRកូដ ដូចខាងក្រោម)
https://www.youtube.com/watch?v=qA0qVg408nM

**វីដេអូស្ដីអំពីការហ្វឹកហ្វឺនដើម្បីប្រលងវាយតម្លៃពលករជំនាញលេខ1 ក្នុងវិស័យសម្អាតអគារ**
(លោកអ្នកអាចចូលមើលក្នុងគេហទំព័រ ឬ QRកូដ ដូចខាងក្រោម)
https://www.youtube.com/watch?v=NMfBxYNpsUA

## (8)ខ្លឹមសារនៃការប្រលងវាយតម្លៃពលករជំនាញលេខ1 ក្នុងវិស័យសម្អាតអគារ

　នៅក្នុងការប្រលងវាយតម្លៃពលករជំនាញលេខ1 មានការប្រលងវិនិច្ឆ័យ និង ការប្រលងជំនាញជាក់ស្តែង។

　នៅទីនេះ យើងនឹងធ្វើការណែនាំអំពីវិញ្ញាសារប្រលងកាលពីមុន។

**ឧទាហរណ៍នៃការប្រលងវិនិច្ឆ័យ (ធ្វើឡើងជាភាសាជប៉ុន)**

(លោកអ្នកអាចចូលមើលក្នុងគេហទំព័រ ឬ QRកូដ ដូចខាងក្រោម)

https://www.j-bma.or.jp/wp-content/uploads/2019/12/2019tokutei_mondai_v2.pdf

**ឧទាហរណ៍នៃការប្រលងជំនាញជាក់ស្តែង (ធ្វើឡើងជាភាសាជប៉ុន)**

　ឧបករណ៍សម្រាប់សម្អាត ត្រូវបានរៀបចំនៅកន្លែងប្រលង។

　ពេលប្រលង អ្នកត្រូវប្រើឧបករណ៍ទាំងនោះដើម្បីធ្វើការងារជាក់ស្តែងមួយចំនួន ដូចខាងក្រោម៖

(លោកអ្នកអាចចូលមើលក្នុងគេហទំព័រ ឬ QRកូដ ដូចខាងក្រោម)

https://x.gd/SiwL3

■ សេវាគាំទ្រការទទួលយកជនបរទេសរបស់ ASCF
ដែលផ្តល់ដោយមជ្ឈមណ្ឌលបណ្តុះបណ្តាលការគ្រប់គ្រងអគារ BMTC
 ក្នុងការទទួលយកពលករជំនាញបរទេសក្នុងវិស័យសម្អាតអគារ
BMTCមជ្ឈមណ្ឌលបណ្តុះបណ្តាលការគ្រប់គ្រងអគារទូទៅបានបង្កើតមជ្ឈមណ្ឌលគាំទ្រការទ

ទួលយកពលករបរទេស ASCFយើងផ្តល់សេវាកម្មយ៉ាងទូលំទូលាយៈ 1) ការគាំទ្រសម្រាប់ការណែនាំ និងជ្រើសរើសធនធានមនុស្សដែលសមស្រប 2) ការគាំទ្រផ្នែកបណ្តុះបណ្តាលសម្រាប់បុគ្គលិកដែលអាចចូលរួមចំណែកដល់ក្រុមហ៊ុនភ្លាមៗ 3) ការគាំទ្រសម្រាប់ការរក្សាបុគ្គលិកបន្ទាប់ពីជ្រើសរើស (ឯកសារភ្ជាប់) ។

លើសពីនេះ យើងនឹងផ្តល់ប្រព័ន្ធសម្រាប់គាំទ្រ ការជ្រើសរើសបុគ្គលិក ការបណ្តុះបណ្តាល និងការរក្សាធនធានមនុស្សសម្រាប់គ្រប់ទិដ្ឋភាពនៃការងារថែទាំអគារ រួមទាំងបុគ្គលិកក្រៅប្រទេសដែលចូលរួមក្នុងការគ្រប់គ្រងគ្រឿងបរិក្ខាអគារមិនកំណត់ចំពោះការសម្អាតអគារផងដែរ1. លក្ខណៈពិសេស

(1) អង្គការដែលទទួលបានអាជ្ញាប័ណ្ណសម្រាប់អាជីវកម្មរកកម្រៃសេវាការងារ និងអាជីវកម្មគាំទ្រការចុះឈ្មោះ។

(2) អង្គការដែលមានបទពិសោធន៍ 50 ឆ្នាំក្នុងការផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងការសម្អាតអគារ

(3)អង្គការត្រូវមានប្រវត្តិនៃការផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈទូទាំងប្រទេសក្នុងការគ្រប់គ្រងអគារ។

2. សេវាកម្មផ្តល់ជូន

(1) សេវាកម្មស្វែងរកការងារដូចជា ការណែនាំ និងការសម្រុះសម្រួលធនធានមនុស្សជនបរទេស

(2)សេវាអប់រំសម្រាប់ពង្រឹងសមត្ថភាពធនធានមនុស្សបរទេស បណ្តុះបណ្តាល និងរៀបចំពួកគេសម្រាប់ការប្រឡង

* BMTC ស្តង់ដារបណ្តុះបណ្តាលធនធានមនុស្សបរទេស

① វគ្គបណ្តុះបណ្តាលជាក់ស្តែង និងទ្រឹស្តីស្តីពីការសម្អាតអគារ និងការគ្រប់គ្រងអគារ

② ឧបករណ៍ជំនួយផ្នែកអប់រំ (ការហ្វឹកហាត់សាច់ដុំបែបសុគីណុ សូកូការ៉ាជំនាញសន្ទនា។ល។)

(3) សេវាគាំទ្រការចុះឈ្មោះសម្រាប់ធនធានមនុស្សបរទេស (ពលករជំនាញ) ការណែនាំជាមុន ការជួបសំណេះសំណាលទៀងទាត់ ការបកប្រែ

(4) សេវាគាំទ្រ និងលើកកម្ពស់ការទទួលយកធនធានមនុស្សបរទេស

①ឧបករណ៍ដែលបានអភិវឌ្ឍរួមគ្នា (Glocal, SmartTraining, BillBuddy)

② ឧបករណ៍គាំទ្រភាពជាដៃគូ (CQI, Oyraaa, Leopalace21, ការគាំទ្រលំនៅដ្ឋានសម្រាប់ជនបរទេស។ល។)

③សេវាកម្មបកប្រែ

3. សេវាកម្មសម្រាប់អ្នក គោលដៅជាក់លាក់

| | |
|---|---|
| 1) ក្រុមហ៊ុនទទួលយក | ការណែនាំការងារ ការអប់រំ ជំនួយការចុះឈ្មោះ និងសេវាកម្មលើកកម្ពស់ការគាំទ្រការទទួលយក |
| 2) ធនធានមនុស្សបរទេស | ការអប់រំ ជំនួយការចុះឈ្មោះ និងសេវាកម្មលើកកម្ពស់ការគាំទ្រការទទួលយក |

| | |
|---|---|
| 3) ស្ថាប័នគាំទ្រការចុះឈ្មោះ | ការណែនាំការងារ ការអប់រំ ជំនួយការចុះឈ្មោះ និងសេវាកម្មលើកកម្ពស់ការគាំទ្រការទទួលយក |
| 4) អង្គការត្រួតពិនិត្យ | ការណែនាំការងារ ការអប់រំ និងសេវាកម្មលើកកម្ពស់ការគាំទ្រការទទួលយក |
| 5) ស្ថាប័នបញ្ជូន | សេវាកម្មណែនាំ ការងារ និងការអប់រំ |

4. ការសាកសួរព័ត៌មាន

< BMTC: មជ្ឈមណ្ឌលបណ្តុះបណ្តាលការគ្រប់គ្រងអគារទូទៅ >

5F Building Maintenance Hall, 5-12-5 Nishi-Nippori, Arakawa-ku, Tokyo 116-0013

TEL: 03-3805-7575 https://bmtc.or.jp/

< ASCF : មជ្ឈមណ្ឌលគាំទ្រការទទួលយកពលករបរទេស >

នៅខាងក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាលការគ្រប់គ្រងអគារទូទៅ

TEL: 03-6806-8685 FAX:03-3805-7578



## 4ការណែនាំអំពីផ្តល់ជំនួយក្នុងការចូល ប្រទេសជប៉ុន និង ការផ្តល់ជំនួយផ្នែករស់នៅ

ករណីធ្វើការជា “ពលករជំនាញលេខ1” លោកអ្នកនឹងអាចទទួលបានជំនួយដើម្បីចូលមកកាន់ប្រទេសជប៉ុន និង ជំនួយផ្នែករស់នៅ ពីសំណាក់ក្រុមហ៊ុន និង ស្ថាប័នគាំទ្រការចុះឈ្មោះដែលជាដៃគូសហការរបស់ក្រុមហ៊ុន ដូចខាងក្រោម៖

1. បន្ទាប់ពីបានចុះកិច្ចសន្យាជាមួយនឹងក្រុមហ៊ុនរួច លោកអ្នកអាចទទួលបានការពន្យល់អំពីខ្លឹមសារកិច្ចសន្យា និង ខ្លឹមសារការងារពីក្រុមហ៊ុន នៅមុនពេលស្នើសុំទិដ្ឋាការបាន។
2. នៅពេលមកដល់ប្រទេសជប៉ុន បុគ្គលិកក្រុមហ៊ុននឹងមកទទួលលោកអ្នកនៅអាកាសយានដ្ឋាន ហើយជូនទៅដល់ក្រុមហ៊ុន និង កន្លែងស្នាក់នៅ។ ហើយនៅពេលដែលត្រឡប់ទៅប្រទេសរបស់ខ្លួនវិញ បុគ្គលិកក្រុមហ៊ុននឹងជួយសម្រួលនៅកន្លែងឆែកសុវត្ថិភាពរបស់អាកាសយានដ្ឋាន។
3. បុគ្គលិកក្រុមហ៊ុននឹងធ្វើជាអ្នកធានាពេលជួលផ្ទះ ឬឱ្យជួលផ្ទះក្រុមហ៊ុន (លំនៅដ្ឋានរបស់ក្រុមហ៊ុន) ថែមទាំងជួយបង្កើតគណនីធនាគារ និងជួយធ្វើកិច្ចសន្យាប្រើប្រាស់ទូរស័ព្ទដៃ អគ្គិសនី និង ហ្គាស។
4. បុគ្គលិកក្រុមហ៊ុននឹងបង្រៀនអំពីច្បាប់ និងទំនៀមទម្លាប់របស់ប្រទេសជប៉ុន។ ហើយពួកគេនឹងបង្រៀនពីរបៀបជិះឡានក្រុង រថភ្លើង និង វិធីសាស្ត្រការពារខ្លួនពីគ្រោះរញ្ជួយដី ជាដើម។
5. បុគ្គលិកក្រុមហ៊ុននឹងទៅជាមួយ នៅសាលាក្រុង និង នីតិវិធីក្នុងការបង់ពន្ធ។ ហើយពួកគេនឹងជួយក្នុងការបំពេញឯកសារនីតិវិធីនានា។
6. បុគ្គលិកក្រុមហ៊ុននឹងណែនាំសាលារៀនដើម្បីរៀនភាសាជប៉ុន ជាដើម។
7. នៅពេលដែលអ្នកជួបបញ្ហាលំបាក អ្នកនឹងទទួលបានការពិភាក្សា និង ផ្តល់យោបល់ជាភាសាកំណើតរបស់អ្នក។
8. បុគ្គលិកក្រុមហ៊ុននឹងបង្កើតឱកាស ណែនាំ អំពីពិធីបុណ្យប្រពៃណីដែលនៅក្បែរៗនោះ ព្រមទាំងឱកាសក្នុងការនិយាយភាសាជប៉ុនជាមួយអ្នកជិតខាង។
9. នៅពេលដែលលោកអ្នកត្រូវបានបញ្ឈប់ពីការងារ ក្រុមហ៊ុននឹងផ្តល់ជំនួយក្នុងការស្វែងរកការងារថ្មី។
10. កិច្ចប្រជុំជាមួយនឹងប្រធានផ្នែកជំនួយរបស់ក្រុមហ៊ុន ត្រូវបានធ្វើជាប្រចាំ។ ដូចនេះ ប្រសិនបើមានបញ្ហាទាក់ទងនឹងការងារ អ្នកអាចពិភាក្សាអំពីបញ្ហាទាំងនោះបាន។

ប្រភព៖ ទីភ្នាក់ងារសេវាអន្តោប្រវេសន៍ “សៀវភៅណែនាំពលករជំនាញ” (សម្រាប់ជនបរទេស) [3]

[3] "សៀវភៅណែនាំអំពីពលករជំនាញ " របស់ទីភ្នាក់ងារសេវាកម្មអន្តោប្រវេសន៍ (សម្រាប់ជនបរទេស)( https://www.moj.go.jp/isa/content/930006034.pdf )កាលបរិច្ឆេទចូលប្រើចុងក្រោយ៖ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០២៤

# 5សេចក្ដីបញ្ចប់

ការងារផ្នែក«សម្អាតអគារ»នៅប្រទេសជប៉ុន គឺជាប្រភេទការងារជួយទ្រទ្រង់ផ្នែកសុខភាពសម្រាប់ការរស់នៅរបស់មនុស្សគ្រប់រូប ដោយរក្សានូវភាពស្អាត និងអនាម័យបរិស្ថានក្នុងអគារ។ "Omotenashi" - ការបង្កើតបរិស្ថានអនាម័យ និងស្អាត និងការស្វាគមន៍ភ្ញៀវ - ឥឡូវនេះបានក្លាយជាវប្បធម៌ជប៉ុនដែលយើងអាចមានមោទនភាពនៅជុំវិញពិភពលោក។

នៅពេលប្រើប្រាស់ប្រព័ន្ធ ពលករជំនាញលេខ1 តាមរយៈការទទួលបានបច្ចេកវិទ្យាសម្អាតអគាររបស់ប្រទេសជប៉ុន ពួកគេអាចស្វែងយល់ពីរបៀប ហើយអាច"ជំរុញអាជីពរបស់ពួកគេនៅក្នុងប្រទេសជប៉ុន" ឬ"ចាប់ផ្តើមអាជីវកម្មបរិស្ថាននៅក្នុងប្រទេសកំណើតរបស់ពួកគេ" ។

យើងសង្ឃឹមថាអ្នកនឹងប្រើសៀវភៅណែនាំនេះ ដើម្បីបង្កើនការយល់ដឹងរបស់អ្នកអំពីការងារក្នុងវិស័យសម្អាតអគារ។